# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៧៤...សសរ...

## សេចក្ដីសំរេច

## ស្ដីពី

## ការទទួលស្គាល់ជាផ្លូវការនូវសមាសភាព សហប្រធានក្រុមការងារទាំង០៨ និងអនុក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម ផ្នែកឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ១៤៩ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសេចក្ដីសំរេចរបស់រាជរដ្ឋាភិបាលលេខ ២៧ សសរ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្ដីពីការកែសំរួលសេចក្ដីសំរេច ស្ដីពីការបង្កើតគណៈកម្មាធិការ អនុគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន និងក្រុមការងារតាមវិស័យសំរាប់ធ្វើជាដៃគូពិភាក្សាជាមួយផ្នែកឯកជន
- យោងសេចក្ដីសំរេចរបស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើតគណៈកម្មការជំរុញការនាំចេញកសិផល លេខ ២១ សសរ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៦ និងសេចក្ដីសំរេចបន្ថែមសមាសភាពលេខ ៣៥ សសរ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩

- យោងកិច្ចប្រជុំផ្សព្វផ្សាយឯកសារគោលនយោបាយ ស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ នាថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១០ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងស្មារតីនៃកិច្ចប្រជុំរវាងគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន ជាមួយផ្នែកឯកជន នាថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១០
- យោងលិខិតសភាពាណិជ្ជកម្មលេខ ០៨៦/១០ សភពណ.កជ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ និងចំណាររបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១០
- អនុលោមតាមតំរូវការចាំបាច់នៃការងារ

## សំរេច

**ប្រការ១** : ទទួលស្គាល់ជាផ្លូវការនូវសមាសភាពសហប្រធានក្រុមការងារទាំង០៨ របស់ផ្នែកឯកជន ដូចខាងក្រោម :

| | |
|---|---|
| ១- ឯកឧត្តម ឧកញ៉ាបណ្ឌិត **ម៉ុង ឫទ្ធី** | សហប្រធានក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម |
| ២- លោក **ហូ វណ្ណី** | សហប្រធានក្រុមការងារផ្នែកទេសចរណ៍ |
| ៣- ឧកញ៉ា **តែ តាំងប៉ោ** | សហប្រធានក្រុមការងារផ្នែកកម្មន្តសាល និងសហគ្រាសធុនតូច និងមធ្យម |
| ៤- លោក **ប្រេតុន ជី.ស្នាវ៉ូនី** | សហប្រធានក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច |
| ៥- លោក **អ៊ិន ចាន់នី** | សហប្រធានក្រុមការងារផ្នែកសេវាធនាគារ និងហិរញ្ញវត្ថុ |
| ៦- ឧកញ៉ា **សូ ខូន** | សហប្រធានក្រុមការងារផ្នែកថាមពល ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន |
| ៧- លោក **ថាន់ ស៊ូអឿង** | សហប្រធានក្រុមការងារផ្នែកផលិតកម្មកែច្នៃសំរាប់នាំចេញ និងកិច្ចសំរួលពាណិជ្ជកម្ម |
| ៨- លោកបណ្ឌិត **ណរាន សុធី** | សហប្រធានក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ |

**ប្រការ២** : សមាសភាពផ្សេងៗទៀត ក្នុងក្រុមការងារនីមួយៗ របស់ផ្នែកឯកជន ជាសិទ្ធិសំរេចរបស់សភាពាណិជ្ជកម្មកម្ពុជា ដែលត្រូវមានការពិភាក្សាឯកភាពគ្នាជាមួយសហប្រធាននៃក្រុមការងារសាមី ដោយឈរលើលក្ខណៈវិនិច្ឆ័យមួយចំនួនច្បាស់លាស់ មានជាអាទិ៍ : និរន្តរភាព-ប្រសិទ្ធភាព-ភាពជាតំណាង ។ល។ នៃមុខវិជ្ជាជីវៈនីមួយៗ ។

**ប្រការ៣** : ទទួលស្គាល់អនុក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម របស់ផ្នែកឯកជន ដោយមាន :

- លោក **ឧកញ៉ា គួ ពុយ** ប្រធានសហព័ន្ធសមាគមរោងម៉ាស៊ីនកិនស្រូវកម្ពុជា ជា **សហប្រធាន**

សំរាប់ធ្វើជាដៃគូសហការជាមួយសមភាគីរបស់រាជរដ្ឋាភិបាល ក្នុងការពិភាក្សានិងសំរេចជ្រើសរើសពូជ-បច្ចេកទេសដាំដុះ ការថែទាំ ការងារស្វែងរកទីផ្សារ សំរាប់ការនាំចេញកសិផល ក្នុងនោះសំខាន់គឺ**ការនាំចេញអង្ករ** ដោយយកចិត្តទុកដាក់ចាប់តាំងពីពេលដាំដុះ ថែទាំ ប្រមូលផល ការរក្សាទុករហូតដល់ការកែច្នៃ វេចខ្ចប់ សំរាប់បំរើការនាំចេញ អោយស្របតាមស្តង់ដារកំណត់ ។

សមាសភាពផ្សេងៗទៀត នៃអនុក្រុមការងារខាងលើនេះ ជាសិទ្ធិសំរេចរបស់សភាពាណិជ្ជកម្មកម្ពុជា រួមជាមួយក្រុមការងារសាមី ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ ក្នុងទិសដៅជំរុញការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការនាំចេញអង្ករ អោយមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ៤** : សមាសភាពនៃក្រុមការងារទាំង០៨ ដូចមានចែងក្នុងប្រការ១ នឹងត្រូវបញ្ចប់អាណត្តិរបស់ខ្លួន នៅពេលសហប្រធានថ្មី ចូលជំនួស តាមរយៈការរៀបចំជ្រើសរើសស្របតាមនីតិវិធីកំណត់ របស់សភាពាណិជ្ជកម្មកម្ពុជា។

**ប្រការ៥** : សហប្រធាន និងសមាសភាពក្រុមការងាររបស់ផ្នែកឯកជន មានភារកិច្ច ដូចខាងក្រោម :

១- ពិភាក្សាក្នុងក្រុមការងារដើម្បីប្រមូលផ្តុំនូវរាល់បញ្ហាដែលមានចរិតជាគន្លឹះ សំរាប់លើកឡើងជាមួយក្រុមការងារ របស់រាជរដ្ឋាភិបាលជាដៃគូឬសំរាប់លើកឡើងនៅពេលមានការប្រជុំពេញអង្គរបស់វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន តាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

២- ចូលរួមប្រជុំ តាមកម្មវិធីកំណត់របស់សហប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាល ដើម្បីចូលរួមដោះស្រាយនូវរាល់បញ្ហាដែលជាកង្វល់ ឬជាឧបសគ្គរបស់ធុរជនជាទូទៅ ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន។

មានតែបញ្ហាមិនអាចដោះស្រាយបាន ក្នុងក៏រិតក្រុមការងារប៉ុណ្ណោះ ដែលអាចត្រៀមសំរាប់បញ្ចូលក្នុងរបៀបវារៈនៃការប្រជុំពេញអង្គរបស់វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន នាពេលបន្ទាប់។

**ប្រការ៦** : ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី - រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម - រដ្ឋមន្ត្រីគ្រប់ក្រសួង - គ្រប់អភិបាលខេត្ត/ក្រុង - គ្រប់ប្រធានស្ថាប័ន/អង្គភាពដែលពាក់ព័ន្ធ សភាពាណិជ្ជកម្មកម្ពុជា និងសមាសភាពដូចមានចែងក្នុងប្រការ១ និងប្រការ៣ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចំលងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ប្រធាន "ក.អ.ក"
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ